**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១១០៥ ព.ណ.ក.កសប

ថ្ងៃច័ន្ទ ១២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦

**ជម្រាបមក**
**លោក/លោកស្រី ប្រធានក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ឯ.ក**

**កម្មវត្ថុ** ៖ករណីស្នើសុំការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្ត ពាក់ម៉ាក **“FORD”** និង “ ”។

**យោង** ៖-ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
-ប្រកាសលេខ ០១១៧ ព.ណ កសប ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក
-លិខិតស្នើសុំរបស់ក្រុមហ៊ុន **អ អិម អេ (ខេមបូឌា) ឯ.ក** ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦
-លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន FORD MOTOR COMPANY ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក/លោកស្រីប្រធានក្រុមហ៊ុនជ្រាបថា យោងតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា៣ និងមាត្រា១១ និងយោងតាមប្រកាសស្តីពី នីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកដែល ប្រការ៨ ចែងថា ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក អ្នកស្នើសុំត្រូវចុះបញ្ជីម៉ាកនៅក្រសួងពាណិជ្ជកម្ម។

ក្នុងករណីដែលក្រុមហ៊ុនបានចុះបញ្ជីម៉ាក **“FORD”** និង “ ” អាចធ្វើការស្នើសុំកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខចំពោះតែម៉ាក **“FORD”** និង “ ” ប៉ុណ្ណោះ។ ចំពោះប្រភេទរថយន្តដែលមានម៉ាកនៃម៉ូដែលជាច់ដោយឡែកជ្រកក្រោមម៉ាក **“FORD”** និង “ ” ដូចជា ម៉ាក EDGE, EQUATOR, MONDEO, TAURUS។ល។ ត្រូវធ្វើការចុះបញ្ជីម៉ាកនៃម៉ូដែលនោះជាមុនសិន ក្នុងករណីដែលត្រូវស្នើសុំកត់ត្រាសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខចំពោះម៉ាកនៃម៉ូដែលនីមួយៗនៅក្រសួងពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុនជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាព។

សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រាជា**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# បញ្ជីម៉ូដែលភ្ជាប់ ម៉ាក “Ford” និង “ Ford ”

| ល.រ | ឈ្មោះ ម៉ូដែល | ស៊េរីម៉ូដែល |
|---|---|---|
| 1 | Bronco | Bronco (BEV) |
| | | Bronco (EREV) |
| | | Big Bend |
| | | Outer Banks |
| | | Badland |
| 3 | Edge | Edge L Trend (FHEV) |
| | | Edge L Titanium (FHEV) |
| | | Edge L |
| 4 | Equator | Equator (PHEV) |
| | | Sport (PHEV) |
| 5 | Everest | Active |
| 6 | Expedition | Active |
| | | Tremor |
| 7 | F-150 | Platinum |
| 8 | Mustang | Fastback |
| | | Premium |
| | | GT Fastback |
| | | GT Premium Fastback |
| | | Dark Horse |
| | | Dark Premium |
| 9 | Mondeo | Mondeo (FHEV) |
| 10 | Ranger | Stormtrak |
| | | Sport |
| | | Platinum |
| | | Super Duty |
| 11 | Taurus | Taurus Ambiente (ICE) |
| | | Taurus Ambiente (FHEV) |
| | | Taurus Trend (ICE) |
| | | Taurus Trend (FHEV) |
| | | Taurus Titanium (ICE) |
| | | Taurus Titanium (FHEV) |
| 12 | Territory | Territory Trend (FHEV) |
| | | Territory Titanium (FHEV) |
| | | Territory Trend (ICE) |
| | | Territory Titanium (ICE) |
| 13 | Transit | Custom |
| | | Connect |
| | | Van |